ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកសិកម្ម

# គោលការណ៍ណែនាំបច្ចេកទេស
# ស្តីពីការត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំ
# គម្របដីតាមប្រព័ន្ធធានាគុណភាពពូជដំណាំ (ប.គ.ព)





រៀបចំដោយៈ នាយកដ្ឋានពូជដំណាំ និងនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម

សហការគាំទ្រដោយៈ

swisscontact
ISA innovation for sustainable agriculture
cirad AGRICULTURAL RESEARCH FOR DEVELOPMENT
Agroecology and Safe Food System Transitions
France AFD
Co-funded by the European Union
FONDS FRANÇAIS POUR L'ENVIRONNEMENT MONDIAL

ឆ្នាំ២០២៥

# អារម្ភកថា

ពូជដំណាំ គឺជាកត្តាកំណត់ដំបូងគេនៅក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្ម ដែលជំរុញឱ្យទទួលបានទិន្នផលខ្ពស់ប្រកបដោយគុណភាព។ ក្រៅពីពូជដំណាំដែលដាំដុះសម្រាប់យកផលិតផល ក៏មានប្រភេទពូជដំណាំគម្របដីដែលត្រូវបានប្រើប្រាស់សម្រាប់កែលម្អគុណភាពដី ទប់ស្កាត់ការហូរច្រោះដី កម្ចាត់ស្មៅចង្រៃ និងបង្កើនជីវៈចម្រុះនៅក្នុងប្រព័ន្ធបរិស្ថានដំណាំនិងដី។

ក្នុងគោលបំណងនៃការបំផុសគំនិតអភិរក្សធនធានធម្មជាតិ និងអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដំណាំគម្របដីបានក្លាយជាជម្រើសដ៏សំខាន់មួយសម្រាប់កសិករ ក្នុងការជួយអភិរក្សដីឱ្យមានផលិតភាពបានយូរអង្វែង និងជួយបង្កើនចំណូលសម្រាប់គ្រួសារកសិករ។ ក្នុងបរិបទបម្រែបម្រួលអាកាសធាតុដែលកំពុងកើតឡើង ការដាំដំណាំគម្របដីជាជម្រើសដ៏ឆ្លាតវៃសម្រាប់កសិកម្ម គ្រប់គ្រងធនធានដីនិងជីជាតិដីប្រកបដោយនិរន្តរភាព ប្រសិទ្ធភាពសេដ្ឋកិច្ច និងភាតរបរិស្ថាន។

ក្នុងពេលថ្មីៗនេះ ដំណាំគម្របដីត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា ដែលត្រូវបានដាំដុះមុនពេលឬចន្លោះវដ្តនៃដំណាំចម្បង (ស្រូវ សណ្ដែកសៀង ពោត ចន្ទី...) ដើម្បីបង្កើនសារធាតុសរីរាង្គក្នុងដី ជួយថែរក្សាជីជាតិនិងសារធាតុចិញ្ចឹមរបស់ដី រក្សាសំណើមដល់ដី និងកាត់បន្ថយការលូតលាស់របស់ស្មៅចង្រៃ។

ដើម្បីជំរុញការប្រើប្រាស់គ្រាប់ពូជដំណាំគម្របដីឱ្យទទួលបានគុណភាពខ្ពស់ អគ្គនាយកដ្ឋានកសិកម្មបានរៀបចំគោលការណ៍ណែនាំបច្ចេកទេសស្ដីពីការត្រួតពិនិត្យគុណភាពគ្រាប់ពូជគម្របដី តាមប្រព័ន្ធធានាគុណភាពពូជដំណាំ (ប.គ.ព) ដោយទទួលបានការគាំទ្រថវិកាពីអង្គការ Swisscontact។ គោលការណ៍ណែនាំនេះ នឹងប្រើប្រាស់ជាឯកសារគោលក្នុងការត្រួតពិនិត្យនិងបញ្ជាក់គុណភាពផលិតកម្ម ការធ្វើអាជីវកម្ម ការបណ្ដុះបណ្ដាល ការផ្សព្វផ្សាយ និងការប្រើប្រាស់តាមស្ថានភាពជាក់ស្ដែង។

អគ្គនាយកដ្ឋានកសិកម្ម មានជំនឿយ៉ាងមុតមាំថា ឯកសារបច្ចេកទេសនេះ នឹងផ្ដល់ផលប្រយោជន៍យ៉ាងសំខាន់ដល់គ្រប់ភាគីពាក់ព័ន្ធ សម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងផលិតពូជដំណាំគម្របដីនៅកម្ពុជា ប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់ ដើម្បីចូលរួមចំណែកបង្កើនផលិតភាពនិងលើកកម្ពស់គុណភាពកសិផលឆ្លើយតបតាមតម្រូវការទីផ្សារជាតិនិងអន្តរជាតិ សំដៅរួមចំណែកលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព កែលម្អជីវភាពរស់នៅរបស់ប្រជាជន និងរក្សាកំណើនសេដ្ឋកិច្ចជាតិ។

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០២៥

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ងិន ឆាយ**

# សមាសភាពក្រុមការងារ

| ល.រ | ឈ្មោះ | តួនាទី | ស្ថាប័ន |
|---|---|---|---|
| ១ | លោក អោម ពេជ្រ | ប្រធាននាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ២ | លោកបណ្ឌិត សេង វ៉ាង | ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម | អគ្គនាយកដ្ឋានកសិកម្ម |
| ៣ | លោកស្រីបណ្ឌិត ស៊្រុន ខេម៉ា | អនុប្រធាននាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ៤ | លោក ឡាង សារឿន | ប្រធានការិយាល័យនៃនាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ៥ | លោក ធីម ធួក | អនុប្រធានការិយាល័យនៃនាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ៦ | កញ្ញា សូរ ចន្ថា | អនុប្រធានការិយាល័យនៃនាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ៧ | លោក ជូ ចាន់ភក្តី | អនុប្រធានការិយាល័យនៃនាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ៨ | លោកស្រី សៀង ស្រីមុំ | មន្ត្រីនៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម | អគ្គនាយកដ្ឋានកសិកម្ម |
| ៩ | លោក ខ្លូត ធារ៉ា | បុគ្គលិកបច្ចេកទេស | មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍកសិកម្មអភិរក្សកម្ពុជា |
| ១០ | Dr. Florent Tivet | ទីប្រឹក្សាបច្ចេកទេស | មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) |
| ១១ | លោកបណ្ឌិត គង់ វ៉ាដា | អ្នកសម្របសម្រួលគម្រោងអាសិត | មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) |
| ១២ | លោកបណ្ឌិត ដានីញ៉ែល សឺទីយ៉ាវ៉ាន់ នូហ្គ្រាហា | នាយកប្រចាំប្រទេសកម្ពុជា | អង្គការ Swisscontact |
| ១៣ | កញ្ញា រ័ត្ន សេដ្ឋា | អនុប្រធានគម្រោង | អង្គការ Swisscontact |
| ១៤ | លោកស្រី រដ្ឋា រ៉ូហ្សា | មន្ត្រីគម្រោងជាន់ខ្ពស់ | អង្គការ Swisscontact |
| ១៥ | លោក ពេជ្រ កែវនេត្រា | មន្ត្រីគម្រោង | អង្គការ Swisscontact |
| ១៦ | លោក ប៊ន់ ម៉េងហ័រ | មន្ត្រីគម្រោង | អង្គការ Swisscontact |
| ១៧ | លោក សាំង ជ្រូក | មន្ត្រីគម្រោង | អង្គការ Swisscontact |

# ពាក្យបំព្រួញ

| | |
|---|---|
| CA | : (Competency authority) អង្គភាពមានសមត្ថកិច្ច |
| CS | : ចំណាត់ថ្នាក់គ្រាប់ពូជវិញ្ញាបនបត្រ |
| GDA | : អគ្គនាយកដ្ឋានកសិកម្ម |
| PDAFF | : មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត |
| RS | : ចំណាត់ថ្នាក់គ្រាប់ពូជចុះបញ្ជី |
| SP | : អ្នកផលិតគ្រាប់ពូជ |
| QDS | : Quality Declared Seed System |
| ប.គ.ព | : ប្រព័ន្ធធានាគុណភាពពូជដំណាំ |
| NAL | : National Agricultural Laboratory (មន្ទីរពិសោធន៍ជាតិកសិកម្ម) |
| CA | : Conservation Agriculture |
| CARDEC | : Cambodian Conservation Agriculture Research for Development Center |

# មាតិកា


១. សេចក្តីផ្តើម ........ ១

១.១ លក្ខណៈទូទៅ ........ ១

១.២ គោលបំណង ........ ១

១.៣ តួនាទី និងភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យគុណភាព ........ ២

១.៣.១ តួនាទីរបស់មន្ត្រីត្រួតពិនិត្យគុណភាព ........ ២

១.៣.២ ភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យគុណភាព ........ ២

២. សេចក្តីសង្ខេបនៃដំណើរការត្រួតពិនិត្យគុណភាព ........ ៤

២.១ គោលបំណងនៃការត្រួតពិនិត្យគុណភាព ........ ៤

២.២ វិធានការគ្រប់គ្រងគុណភាពគ្រាប់ពូជដំណាំគម្របដី ........ ៤

២.៣ ដំណើរការត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំគម្របដី តាម ប.គ.ព ........ ៥

៣.ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល ........ ៧

៣.១ ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលរបស់ដំណាំគម្របដី ........ ៧

៣.២ បច្ចេកទេសដាំដុះដំណាំគម្របដី ........ ៧

៣.២.១ បច្ចេកទេសដាំដុះដំណាំគម្របដីចង្ក្រង់ស្វាស្លឹកធំ ........ ៧

៣.២.២ បច្ចេកទេសដាំដុះដំណាំគម្របដីចង្ក្រង់ស្វាស្លឹកតូច ........ ៩

៣.២.៣ បច្ចេកទេសដាំដុះដំណាំស្មោរគោក ........ ១១

៣.២.៤ ការត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាល ........ ១២

៣.៣ ផ្ទៀងផ្ទាត់ប្រភពគ្រាប់ពូជ ........ ១២

៣.៤ លក្ខខណ្ឌសម្រាប់ជ្រើសរើសចម្ការផលិតកម្មពូជដំណាំគម្របដី ........ ១៣

៣.៥ ស្តង់ដារគុណភាពផលិតកម្មនៅទីវាល ........ ១៤

៣.៦ ការកំណត់ប្រភេទពូជលាយ ........ ១៥

៣.៧ ការកំណត់ស្មៅហាមឃាត់ ........ ១៥

៣.៨ ការកំណត់ជំងឺហាមឃាត់ ........ ១៦

៣.៩ ការវិនិច្ឆ័យលើដំណាំគម្របដីទទួលរងប៉ះពាល់ដោយសារតែជំងឺហាមឃាត់ ........ ១៦

៤. ការត្រួតពិនិត្យគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍ ........ ១៧

៤.១ ដំណើរការត្រួតពិនិត្យគុណភាពក្នុងមន្ទីរពិសោធន៍ ........ ១៧

៤.២ ការយកសំណាកបឋម ........ ១៧

**៤.៣. ការរៀបចំសំណាកដើម្បីពិសោធន៍ ........ ១៨**

**៤.៤ ការវេចខ្ចប់ និងបិទស្លាកសំណាកបញ្ជូន ........ ១៩**

**៤.៥ ស្តង់ដារគុណភាពគ្រាប់ពូជ ........ ១៩**

៤.៥.១ ស្តង់ដារគុណភាពគ្រាប់ពូជចង្រ្កង់ស្វាស្លឹកធំ ........ ១៩

៤.៥.២ ស្តង់ដារគុណភាពគ្រាប់ពូជចង្រ្កង់ស្វាស្លឹកតូច ........ ២០

៤.៥.៣ ស្តង់ដារគុណភាពគ្រាប់ពូជស្មៅគោក ........ ២០

**៤.៦. ដំណើរការវិភាគសំណាកគ្រាប់ពូជដំណាំតម្រូវចំណី ........ ២០**

៤.៦.១ វិភាគរូបសាស្រ្ត ........ ២១

៤.៦.២ វិភាគប្រភេទពូជ ........ ២១

៤.៦.៣ វិភាគសំណើមគ្រាប់ ........ ២១

៤.៦.៤ វិភាគដំណុះគ្រាប់ ........ ២១

**ឯកសារយោង ........ ២៣**

**ឧបសម្ព័ន្ធ ០១**

ឯកសារយោង និងទម្រង់របាយការណ៍ផ្សេងៗ ........ ២៤

**ឧបសម្ព័ន្ធ ០២**

ឧបករណ៍ និង សម្ភារពិនិត្យគុណភាពគ្រាប់ពូជ ........ ៤០

**ឧបសម្ព័ន្ធ ០៣**

សទ្ទានុក្រម ........ ៤៣

## ១. សេចក្តីផ្តើម

### ១.១ លក្ខណៈទូទៅ

ដំណាំគម្របដី (Cover Crop) ជាប្រភេទដំណាំដែលត្រូវបានគេដាំដុះក្នុងគោលបំណងថែរក្សា និងបង្កើនជីជាតិដី ការពារសំណឹក ការហូរច្រោះ គ្រប់គ្រងស្មៅចង្រៃ រក្សាសំណើមដី។ ដំណាំគម្របដីមួយចំនួនទៀតក៏ត្រូវបានគេប្រើប្រាស់ជាចំណីសត្វផងដែរ។ ដំណាំគម្របដីគឺជាផ្នែកសំខាន់មួយនៅក្នុងកសិកម្មអភិរក្ស (Conservation Agriculture) ដែលជាការអនុវត្តកសិកម្មដើម្បីចូលរួមលើកកម្ពស់ការគ្រប់គ្រង និងអភិរក្សដីប្រកបដោយចីរភាព កាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន តាមរយៈការទប់ស្កាត់ផលប៉ះពាល់ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ការអនុវត្តកសិកម្មអភិរក្ស មានគោលការណ៍គ្រឹះសំខាន់បីគឺ ការកាត់បន្ថយការរំខានដីឬក្ជួររាស់ ការថែរក្សាដីឱ្យមានគម្របជាអចិន្ត្រៃយ៍ដោយការប្រើប្រាស់ដំណាំគម្របដីឬសំណល់រុក្ខជាតិ និងការអនុវត្តប្រព័ន្ធដំណាំបង្វិល។ កសិកម្មអភិរក្សឬដំណាំគម្របដីត្រូវបានអនុវត្តនិងផ្សព្វផ្សាយចាប់ពីឆ្នាំ២០០៤ ដោយមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍកសិកម្មអភិរក្សកម្ពុជា(CARDEC) នៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម។

ដំណាំគម្របដីត្រូវបានដាំដុះមុនពេល ឬចន្លោះវដ្តលូតលាស់នៃដំណាំចម្បង (ស្រូវ សណ្តែកសៀង ពោតចន្ទី) ដើម្បីបង្កើនសារជាតុមីក្រូសរីរាង្គ ជួយថែរក្សាលំនឹងជីជាតិ និងសារជាតុចិញ្ចឹមក្នុងដី រក្សាសំណើមកដី និងកាត់បន្ថយការលូតលាស់របស់ស្មៅចង្រៃ។ ដំណាំគម្របដី ត្រូវបានដាំដុះឆ្លាស់គ្នាជាមួយនឹងដំណាំចម្បង ដើម្បីទប់ស្កាត់ការហូរច្រោះដី សំណឹកដី និងទប់ស្កាត់ការបាត់បង់សារជាតុចិញ្ចឹមពីក្នុងដី និងបង្កើនសុខភាពរបស់ដី។ បច្ចុប្បន្ន មានកសិករកំពុងដាំដុះដំណាំគម្របដីសម្រាប់ផលិតកម្មពូជ ធ្វើជាអាជីវកម្មបន្ទាប់ពីដំណាំចម្បង។ ដំណាំគម្របដីមានច្រើនអំបូរ ក្រុម និងប្រភេទពូជ ដែលក្នុងនោះ ពូជដំណាំគម្របដីនីមួយៗ គឺត្រូវបានគេជ្រើសរើសដើម្បីដាំដុះផ្អែកទៅតាមស្ថានភាពដី អាកាសធាតុ និងវត្ថុបំណងផ្សេងៗ។

ដំណាំគម្របដីមានជាច្រើនប្រភេទពូជនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែដំណាំគម្របដី ចំនួន ១៥ពូជ ត្រូវបានចុះបញ្ជិកាក្នុងបញ្ជីប្រភេទពូជដំណាំជាតិ ក្រោមការគាំទ្រដោយគម្រោងវិវឌ្ឍនាការកសិអេកូឡូស៊ី និងប្រព័ន្ធស្បៀងអាហារសុវត្ថិភាព(ASSET)ប្រចាំប្រទេសកម្ពុជា។ ដើម្បីធ្វើអាជីវកម្មពូជដំណាំគម្របដី អាជីវករ ឬផលិតករចាំបាច់ត្រូវអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ តាមរយៈការស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មកែច្នៃពូជដំណាំ ការធ្វើផែនការផលិតកម្ម ការស្នើសុំត្រួតពិនិត្យគុណភាពទីវាល ការស្នើសុំត្រួតពិនិត្យគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍ជាតិកសិកម្ម និងការស្នើសុំស្លាកសញ្ញាបញ្ជាក់គុណភាពនៅអគ្គនាយកដ្ឋានកសិកម្ម។

### ១.២ គោលបំណង

គោលការណ៍ណែនាំបច្ចេកទេសស្តីពីការត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំគម្របដី តាមប្រព័ន្ធធានាគុណភាពពូជដំណាំ(ប.គ.ព)ត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រើប្រាស់ជាឯកសារគោល សម្រាប់បណ្តុះបណ្តាល គ្រូបង្គោល និងបណ្តុះបណ្តាលបន្ត រាល់ភាគីពាក់ព័ន្ធ និងជាឯកសារយោងដ៏សំខាន់សម្រាប់មន្ត្រីត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំគម្របដីនៃអង្គភាពមានសមត្ថកិច្ច ក្នុងការប្រតិបត្តិការសម្រាប់ផលិតកម្ម និងអាជីវកម្មគ្រាប់ពូជដំណាំគម្របដី។

### ១.៣ តួនាទី និងភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យគុណភាព

#### ១.៣.១ តួនាទីរបស់មន្ត្រីត្រួតពិនិត្យគុណភាព

តួនាទីសំខាន់របស់មន្ត្រីត្រួតពិនិត្យគុណភាព គឺមានភាតព្វកិច្ចដើម្បីចុះវាយតម្លៃគុណភាពផលិតកម្មគ្រាប់ពូជដំណាំគម្របដី នៅទីវាល ឬចម្ការផលិតពូជ ដើម្បីផ្ទៀងផ្ទាត់ទៅនឹងពាក្យស្នើសុំក្នុងទម្រង់ (ក) យោងតាមគោលការណ៍បច្ចេកទេស ប.គ.ព ស្តង់ដារទីវាល និងការយកសំណាកគ្រាប់ពូជដំណាំគម្របដី ដើម្បីវិភាគគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍ជាតិកសិកម្ម។

***ចំណាំ៖*** មន្ត្រីត្រួតពិនិត្យគុណភាព មិនមែនជាអ្នកវិភាគគុណភាពគ្រាប់ពូជដំណាំគម្របដីនៅក្នុងមន្ទីរពិសោធន៍ និងមិនមែនជាមន្ត្រីបច្ចេកទេស ក្នុងផលិតកម្មគ្រាប់ពូជដំណាំគម្របដីនោះទេ។

#### ១.៣.២ ភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យគុណភាព

**ក. ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល**

**មុនពេលត្រួតពិនិត្យគុណភាពផលិតកម្មពូជដំណាំគម្របដីក្នុងចម្ការ៖**

- ពិនិត្យពាក្យស្នើសុំក្នុងទម្រង់ (ក) ដែលផ្តល់ឱ្យដោយអ្នកផលិតពូជដំណាំគម្របដី[1] បន្ទាប់មកត្រូវរៀបចំបញ្ជីព័ត៌មានសំខាន់ៗ សម្រាប់ដំណើរការវាយតម្លៃផលិតកម្មគ្រាប់ពូជដំណាំគម្របដីនៅក្នុងចម្ការ
- ណាត់ជួបជាមួយអ្នកផលិតគ្រាប់ពូជ ដើម្បីត្រួតពិនិត្យគុណភាពផលិតកម្មទីវាលយ៉ាងហោចណាស់ឱ្យបានមួយថ្ងៃមុនពេលចុះត្រួតពិនិត្យចម្ការ ឬទីវាលផលិតកម្មគ្រាប់ពូជដំណាំគម្របដី
- ផ្ទៀងផ្ទាត់ព័ត៌មានសំខាន់ៗ ពាក់ព័ន្ធនឹងប្រភេទពូជ ផ្ទៃដីដុះ ទីតាំងចម្ការផលិតកម្ម សម្រាប់ការត្រួតពិនិត្យ
- ជ្រើសរើសដោយចៃដន្យយ៉ាងហោចណាស់ ១០%នៃផ្ទៃដីផលិតកម្មគ្រាប់ពូជដំណាំគម្របដីសរុប យោងតាមប្រភេទពូជ និងចំណាត់ថ្នាក់ពូជនីមួយៗ សម្រាប់ត្រួតពិនិត្យគុណភាពនៅក្នុងចម្ការផលិតកម្មពូជដំណាំគម្របដី
- ផ្ទៀងផ្ទាត់ព័ត៌មានអំពីទីតាំងចម្ការផលិតកម្ម និងកំណត់ពេលវេលាសមស្របសម្រាប់ចុះត្រួតពិនិត្យគុណភាពផលិតកម្មនៅចម្ការ ជាមួយនឹងអ្នកផលិតគ្រាប់ពូជដំណាំគម្របដីដោយផ្ទាល់
- ត្រៀមជាស្រេចនូវឧបករណ៍ និងសម្ភារចាំបាច់ដូចជា ឯកសណ្ឋានការពារថ្នាំកសិកម្ម មធ្យោបាយធ្វើដំណើរ ឧបករណ៍វាស់វែងសំណាក និងទម្រង់របាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មនៅចម្ការផលិតពូជ។

**អំឡុងពេលត្រួតពិនិត្យគុណភាពផលិតកម្មពូជលើទីវាល៖**

- ត្រូវពិនិត្យ អង្កេត និងសាកសួររាល់ព័ត៌មានសំខាន់ៗ ពីអ្នកផលិតគ្រាប់ពូជ ឬតំណាងទាក់ទងនឹងព្រំប្រទល់ចម្ការផលិតកម្មពូជ ប្រភេទពូជ គុណភាព ចំណាត់ថ្នាក់គ្រាប់ពូជ ផ្ទៃដីដាំដុះ និងប្រវត្តិដាំដុះនៃចម្ការ
- ត្រួតពិនិត្យចម្ការផលិតកម្ម ដោយអនុវត្តតាម ប.គ.ព
- វាយតម្លៃប្រភេទពូជដំណាំផ្សេង ពូជលាយ ស្មៅហាមឃាត់ កម្រិតបំផ្លាញដោយជំងឺហាមឃាត់ ស្ថានភាពទូទៅ នៃផលិតកម្មពូជដំណាំគម្របដី ការអនុវត្តជាក់ស្តែងនៅចម្ការផលិតកម្ម និងការប៉ាន់ស្មានទិន្នផលដែលទទួលបាន។សម្គាល់៖ ការត្រួតពិនិត្យគុណភាពពូជដំណាំគម្របដី នៅចម្ការផលិតកម្មត្រូវតែ

[1] អ្នកផលិតគ្រាប់ពូជដំណាំគម្របដី សំដៅបុគ្គល ក្រុម ក្រុមហ៊ុន សហគមន៍កសិកម្ម សមាគម ឬអង្គការក្រៅរដ្ឋាភិបាល ដែលមានគោលបំណងផលិត និងធ្វើធុរកិច្ចគ្រាប់ពូជដំណាំគម្របដី។

អនុវត្តក្នុងចម្ការដដែល លើកលែងតែចម្ការផលិតកម្មដែលបានត្រួតពិនិត្យគុណភាពផលិតកម្មរួច មានជួបប្រទះនូវបញ្ហា ប្រធានសក្តិ ដូចជា ការខូចខាត ឬបំផ្លាញ ដោយសារ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ការបំផ្លាញដោយសត្វល្អិត ឬ ជំងឺបំផ្លាញធ្ងន់ធ្ងរ។ល។

- ផ្តល់អនុសាសន៍ ដល់អ្នកផលិតគ្រាប់ពូជដំណាំគម្របដី សម្រាប់សកម្មភាពកែលម្អ ប្រសិនបើចាំបាច់ ហើយត្រូវបញ្ចូលអនុសាសន៍ទាំងនោះ ទៅក្នុងរបាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មនៅចម្ការ។
- បំពេញរបាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មពូជដំណាំគម្របដីនៅចម្ការ ដោយមានចុះហត្ថលេខារបស់អ្នកផលិតគ្រាប់ពូជ ឬតំណាង និងរក្សាទុក ១(មួយ)ច្បាប់ សម្រាប់អ្នកធ្វើផលិតកម្មគ្រាប់ពូជ ១ ច្បាប់ សម្រាប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត និង១ច្បាប់ទៀត សម្រាប់នាយកដ្ឋានពូជដំណាំ នៃអគ្គនាយកដ្ឋានកសិកម្ម (GDA)។

**ក្រោយពេលត្រួតពិនិត្យគុណភាពផលិតកម្មទីវាល ៖**

- ជូនដំណឹងដល់អ្នកផលិតគ្រាប់ពូជអំពីការបដិសេធលើចម្ការផលិតកម្មពូជដំណាំគម្របដី ករណីរកឃើញថាចម្ការផលិតកម្មនោះ មិនមានគុណភាពគ្រប់គ្រាន់ និងមិនអនុលោមតាមស្តង់ដារទីវាល ប.គ.ព ។

## ខ. ការត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំគម្របដី

**មុនពេលយកសំណាកគ្រាប់ពូជ៖**

- ពិនិត្យពាក្យស្នើសុំក្នុងទម្រង់(ខ) និងណាត់ជួបជាមួយអ្នកផលិតគ្រាប់ពូជដំណាំគម្របដី យ៉ាងហោចណាស់ ២៤ម៉ោង ឬ ១ថ្ងៃ មុនពេលចុះយកសំណាកគ្រាប់ពូជដំណាំគម្របដី
- ផ្ទៀងផ្ទាត់ទម្រង់ (ខ) ទីតាំងស្តុកទុក បរិមាណគ្រាប់ពូជ ប្រភេទពូជ និងចំណាត់ថ្នាក់គ្រាប់ពូជដំណាំគម្របដី ដែលត្រូវយកសំណាក
- កំណត់ឡូតិ៍គ្រាប់ពូជសម្រាប់យកសំណាកបន្ទាប់ពីទទួលបានបញ្ជីឡូតិ៍គ្រាប់ពូជពីអ្នកផលិតគ្រាប់ពូជ
- ត្រៀមជាស្រេចនូវមធ្យោបាយធ្វើដំណើរ និងឧបករណ៍យកសំណាកគ្រាប់ដំណាំគម្របដី ដូចជា ដែកឆាំ ឧបករណ៍វាស់សំណើម ជញ្ជីងថ្លឹង ថាសដាក់គ្រាប់ពូជ ក្រដាសស្អិតក័របិទ ថង់ប្លាស្ទិក ហ្វឺតសរសេរ ម៉ាសពាក់ការពារ ស្រោមដៃ និងវ៉ែនតាការពារភ្នែក។

**អំឡុងពេលយកសំណាកគ្រាប់ពូជ៖**

- យកសំណាកគ្រាប់ពូជដោយចៃដន្យ ចេញពីបាវស្តុកគ្រាប់ពូជដំណាំគម្របដី
- បិទស្លាកសម្គាល់គ្រាប់ពូជដែលបានយកសំណាកឱ្យបានត្រឹមត្រូវសម្រាប់ការវិភាគគុណភាព
- វិភាគគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍ជាតិកសិកម្ម

**ក្រោយពេលយកសំណាកគ្រាប់ពូជ៖**

- សរសេររបាយការណ៍លទ្ធផលនៃការវិភាគគុណភាពគ្រាប់ពូជដំណាំគម្របដី រួចបញ្ជូនទៅនាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម (GDA)។

## ២. សេចក្តីសង្ខេបនៃដំណើរការត្រួតពិនិត្យគុណភាព

### ២.១ គោលបំណងនៃការត្រួតពិនិត្យគុណភាព

- ធ្វើចំណាត់ថ្នាក់ និងជាគម្រូផលិតផលធៀបនឹងស្តង់ដារគុណភាពគ្រាប់ពូជ
- ជំរុញអាជីវកម្មគ្រាប់ពូជដំណាំគម្របដី ប្រកបដោយយុត្តិធម៌ និងប្រសិទ្ធភាព
- បង្ហាញសូចនាករជាក់លាក់អំពីគុណភាពនៃផលិតផលគ្រាប់ពូជដំណាំគម្របដីដល់អ្នកទិញយកទៅផលិតបន្ត

### ២.២ វិធានការគ្រប់គ្រងគុណភាពគ្រាប់ពូជដំណាំគម្របដី

ហានិភ័យមួយចំនួនមានជាប់ ឬលាយឡំជាមួយគ្រាប់ពូជនៅក្នុងដំណើរការផលិតកម្មពូជដំណាំគម្របដី ដែលមន្ត្រីត្រួតពិនិត្យគុណភាព គួរតែពិចារណាស្របតាមនីតិវិធី ប.គ.ព។ ការត្រួតពិនិត្យគុណភាពត្រឹមត្រូវ នឹងអាចបន្ថយហានិភ័យនៃការលាយឡំទាំងនោះបាន។ ដំណើរការត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំគម្របដី រួមមាន៖ (១)ការពិនិត្យឯកសារ (២)ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល (៣)ការយកសំណាកនិងការត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំគម្របដីនៅមន្ទីរពិសោធន៍ និង (៤)ស្វ័យត្រួតពិនិត្យគុណភាពរបស់អ្នកផលិតគ្រាប់ពូជដំណាំគម្របដី ដើម្បីប្រាកដថាភាពសុទ្ធនៃគ្រាប់ពូជដំណាំគម្របដី ដែលត្រូវបានធានា ឬបញ្ជាក់មុនអនុញ្ញាតឱ្យយកទៅប្រើប្រាស់បន្ត។

**តារាង ២.២ លក្ខណៈវិនិច្ឆ័យលើហានិភ័យ និងវិធានការឆ្លើយតប ក្នុងការធានាគ្រាប់ពូជដំណាំគម្របដីសុទ្ធ**

| | ហានិភ័យ | វិធានការ |
|---|---|---|
| ១ | ការលាយឡំជាមួយគ្រាប់ពូជដំណាំគម្របដីផ្សេង | - ប្រើប្រាស់ពូជគ្រាប់សុទ្ធមានគុណភាពល្អ ដែលស្របតាម ស្តង់ដារត្រឹមត្រូវ និងមានប្រភពច្បាស់លាស់ |
| ២ | សំណល់គ្រាប់ពូជផ្សេងក្នុងចម្ការផលិតកម្មពូជដំណាំគម្របដីដែលនៅសល់ពីរដូវកាលដាំដុះមុន | - ជ្រើសរើសដីចម្ការដែលធ្លាប់ដាំប្រភេទពូជដដែល ដូចជា ចង្រ្កង់ស្វាស្លឹកធំ ចង្រ្កង់ស្វាស្លឹកតូច ស្នោរគោក ឬដំណាំផ្សេង ដែលមានអាយុកាលលូតលាស់ខ្លីនិងទំហំគ្រាប់ខុសពីប្រភេទពូជដំណាំទាំង៣ខាងលើ (តូចជាង ឬធំជាង)<br>- ដាំដុះប្រភេទពូជផ្សេងគ្នានៅក្នុងដីចម្ការផ្សេងគ្នា<br>- សម្អាតដីចម្ការដោយទុកឱ្យគ្រាប់ពូជផ្សេងដុះអស់ ប្រើប្រាស់ថ្នាំសម្លាប់ស្មៅជំរើស និងប្រើប្រាស់វិធានការក្សេត្រសាស្ត្រផ្សេងៗទៀត |
| ៣ | ការលាយឡំជាមួយគ្រាប់ពូជមានជំងឺហាមឃាត់ | - គ្រប់គ្រងជំងឺហាមឃាត់ឱ្យបានត្រឹមត្រូវទៅតាមស្តង់ដារទីវាល |
| ៤ | ការលាយឡំជាមួយគ្រាប់ពូជស្មៅហាមឃាត់ | - គ្រប់គ្រងស្មៅឱ្យបានត្រឹមត្រូវទៅតាមស្តង់ដារទីវាល |
| ៥ | ការលាយឡំជាមួយគ្រាប់ពូជដំណាំគម្របដីផ្សេងក្នុងពេលប្រមូលផល | - ទុកគម្លាតចម្ការផលិតកម្មគ្រាប់ពូជចង្រ្កង់ស្វាស្លឹកធំ ចង្រ្កង់ស្វាស្លឹកតូច ស្នោរគោក ឱ្យឆ្ងាយពីចម្ការផលិតកម្មដំណាំគម្របដីប្រភេទដ៏ទៃទៀត |

| | ហានិភ័យ | វិធានការ |
|---|---|---|
| | | - សម្អាតម៉ាស៊ីនច្រូតឬប្រមូលផលឱ្យបានត្រឹមត្រូវ មុនពេលប្រមូលផលគ្រាប់ពូជនីមួយៗ ចង្រ្កង់ស្វាស្លឹកធំ ចង្រ្កង់ស្វាស្លឹកតូច និងស្មៅរគោក។ |
| ៦ | ការលាយជាមួយគ្រាប់ពូជផ្សេង ក្នុងអំឡុងពេលសម្ងួត សម្អាតគ្រាប់ពូជ និងវេចខ្ចប់ | - ពិនិត្យដំណើរការអនុវត្តសកម្មភាពក្រោយប្រមូលផល និងស្វ័យត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំគម្របដីឱ្យបានត្រឹមត្រូវ ចៀសវាងការដែលអាចលាយឡំគ្រាប់ពូជនៅពេលសម្អាត ហាលសម្ងួត និងការវេចខ្ចប់<br>- ពិនិត្យសារឡើងវិញលើសំបកបាវវេចខ្ចប់ជាមួយឈ្មោះ គ្រាប់ពូជ។ |
| ៧ | ការច្រឡំអំឡុងពេលយកសំណាក និងវិភាគគ្រាប់ពូជដំណាំគម្របដី | - ដាក់ស្លាកសម្គាល់ឱ្យបានត្រឹមត្រូវ បន្ទាប់ពីយកសំណាកគ្រាប់ពូជដំណាំគម្របដីរួចរាល់ |
| ៨ | ការវេចខ្ចប់និងបិទស្លាកសញ្ញាខុស | - ពិនិត្យសំបកវេចខ្ចប់គ្រាប់ពូជដំណាំគម្របដីសម្រាប់លក់ ព្រមទាំងស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.ព ដែលត្រូវបិទភ្ជាប់។ |

## ២.៣ ដំណើរការត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំគម្របដី តាម ប.គ.ព



## គំនូសបំព្រួញក្នុងដំណើរការត្រួតពិនិត្យគុណភាពគ្រាប់ពូជដំណាំគម្របដីតាម ប.គ.ព

| អ្នកទទួល | | ឯកសារពាក់ព័ន្ធ |
|---|---|---|
| អ្នកផលិតពូជ ឬ សហគមន៍កសិកម្ម | ការធ្វើផែនការផលិតកម្មគ្រាប់ពូជដំណាំគម្របដី ចុះកិច្ចសន្យាជាមួយកសិករផលិតគ្រាប់ពូជ និងពិនិត្យចម្ការ | |
| តំណាងអ្នកផលិតពូជ>> PDAFF>>DCS | ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ព័ត៌មាន នៃផលិតករគ្រាប់ពូជ និងផែនការរបស់អ្នកផលិតគ្រាប់ពូជ ដំណាំគម្របដី | ឧបសម្ព័ន្ធ 1-A |
| GDA | ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ផ្តល់ជូនដោយ GDA (អំឡុងពេល ២០ថ្ងៃបន្ទាប់ពីទទួលពាក្យស្នើសុំ) | ឧបសម្ព័ន្ធ 1-B |
| តំណាងអ្នកផលិតពូជ>> PDAFF>>DCS | ការដាក់ទម្រង់ (ក)៖ ផែនការផលិតកម្មគ្រាប់ពូជដំណាំគម្របដី ផ្តល់ជូនដោយ GDA ប្រភពគ្រាប់ពូជ ផ្ទៃដីដាំដុះ។ល។ | ឧបសម្ព័ន្ធ 1-C |
| តំណាងអ្នកផលិតពូជ | ដំណើរការផលិតកម្មគ្រាប់ពូជដំណាំគម្របដីក្នុងចម្ការដែលកំណត់ ស្វ័យគ្រប់គ្រងត្រួតពិនិត្យគុណភាពផលិតកម្មទីវាល | |
| មន្ត្រីត្រួតពិនិត្យ DCS | ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល និងការធ្វើរបាយការណ៍ត្រួតពិនិត្យ និងធ្វើរបាយការណ៍ភ្លាមបន្ទាប់ពីត្រួតពិនិត្យ | ឧបសម្ព័ន្ធ 1-D/1-E |
| តំណាងអ្នកផលិតពូជ | ការងារប្រមូលផល និងក្រោយប្រមូលផលពូជដំណាំគម្របដី | |

| អ្នកទទួល | | ឯកសារពាក់ព័ន្ធ |
|---|---|---|
| អ្នកផលិតពូជ | **ត្រួតពិនិត្យគុណភាពក្នុងពេលប្រមូលផល សម្ងួត វេចខ្ចប់ និងរក្សាទុក** | |
| ⇩ | | |
| អ្នកផលិតពូជ | **ស្វ័យចាត់ចែងឡូតិ៍គ្រាប់ពូជដំណាំគម្របដី**<br>ចាត់ចែងគ្រាប់ពូជផ្អែកលើកសិករចុះកិច្ចសន្យា ពូជ ចំណាត់ថ្នាក់គ្រាប់ពូជ រដូវកាល | |
| ⇩ | | |
| អ្នកផលិតពូជ | **ស្វ័យត្រួតពិនិត្យគុណភាពគ្រាប់ពូជបឋម**<br>ភាពសុទ្ធ កម្ទេចកម្ទី គ្រាប់ស្មៅ គ្រាប់ដំណាំផ្សេង សំណើម និងដំណុះគ្រាប់ពូជ | |
| ⇩ | | |
| អ្នកផលិតពូជ>>> PDAFF/GDA | **ការដាក់ទម្រង់ (ខ) ៖ សំណើសុំត្រួតពិនិត្យគុណភាពគ្រាប់ពូជ**<br>ដាក់ជូន PDAFF/GDA | ឧបសម្ព័ន្ធ 1-F |
| ⇩ | | |
| មន្ត្រីត្រួតពិនិត្យ PDAFF/GDA | **ការយកសំណាកសម្រាប់ត្រួតពិនិត្យគុណភាពនៅមន្ទីរពិសោធន៍**<br>ត្រូវយកសំណាកឱ្យបានត្រឹមត្រូវ | |
| ⇩ | | |
| មន្ត្រីត្រួតពិនិត្យ NAL/GDA | **ការវិភាគគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍**<br>ភាពសុទ្ធ កម្ទេចកម្ទី គ្រាប់ស្មៅ គ្រាប់ដំណាំផ្សេង សំណើម និងដំណុះ | |
| ⇩ | | |
| មន្ត្រីត្រួតពិនិត្យ NAL/GDA | **របាយការណ៍វិភាគគុណភាពគ្រាប់ពូជ**<br>បង្ហាញលទ្ធផលវិភាគ និងសេចក្តីសន្និដ្ឋាន | ឧបសម្ព័ន្ធ 1-G/1-F |
| ⇩ | | |
| GDA>>> អ្នកផលិតពូជ | **ការជូនព័ត៌មានអំពីលទ្ធផលនៃការវិភាគគុណភាពគ្រាប់ពូជដល់អ្នកផលិតគ្រាប់ពូជ** | |
| ⇩ | | |
| GDA>>> អ្នកផលិតពូជ | **ការផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.ព**<br>ផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.ព ជូនផលិតករ តាមសំណើសុំត្រួតពិនិត្យគុណភាពគ្រាប់ពូជ (ទម្រង់ ខ) | |

## ៣.ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល

### ៣.១ ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលរបស់ដំណាំគម្របដី

ការត្រួតពិនិត្យគុណភាពផលិតកម្មពូជដំណាំគម្របដីនៅទីវាល ត្រូវធ្វើឡើងចំនួន ១លើក នៅក្នុងអំឡុងពេលផលិតកម្មគឺនៅដំណាក់កាលចេញផ្កា។

### ៣.២ បច្ចេកទេសដាំដុះដំណាំគម្របដី

#### ៣.២.១ បច្ចេកទេសដាំដុះដំណាំគម្របដីចង្រ្កង់ស្វាស្លឹកធំ

**ក. លក្ខណៈទូទៅ**

ចង្រ្កង់ស្វាស្លឹកធំ មានឈ្មោះវិទ្យាសាស្ត្រថា Crotalaria juncea និងឈ្មោះជាភាសាអង់គ្លេសថា Sunnhemp គឺជាប្រភេទរុក្ខជាតិពពួកសណ្តែកមានដើមកំណើតមកពីប្រទេសឥណ្ឌា ហើយវាត្រូវបានដាំដុះយ៉ាងទូលំទូលាយនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍សម្រាប់យកជាតិសរសៃ ធ្វើជាចំណីសត្វ និងកែលម្អដីជាតិដី។ អាយុកាលពីដាំរហូតប្រមូលផល រយៈពេល១០០ទៅ១២០ថ្ងៃ មានកម្ពស់ដើមជាង ២ម៉ែត្រក្នុងរយៈពេល៦០ថ្ងៃ ផ្កាពណ៌លឿង ផ្លែមានរាងស៊ីឡាំង មានរោមប្រវែងប្រហែល ៣-៦សង់ទីម៉ែត្រ អង្កត់ផ្ចិត១-២សង់ទីម៉ែត្រ និងមានពណ៌ត្នោតខ្ចីពេលចាស់។ គ្រាប់ចង្រ្កងស្វាស្លឹកធំមានពណ៌ខ្មៅ រាងជាបេះដូង ប្រវែងប្រមាណ៦ម.ម ចំនួនគ្រាប់ពូជក្នុងមួយគីឡូក្រាមប្រហែល ៣០០០០គ្រាប់។ ចង្រ្កង់ស្វាស្លឹកធំមានការលូតលាស់លឿន ធន់នឹងគ្រោះរាំងស្ងួត មានសមត្ថភាពសំយោគអាសូតពីបរិយាកាស និងប្រើប្រាស់ឡើងវិញនូវសារធាតុចិញ្ចឹម និងសមត្ថភាពគ្រប់គ្រងពពួកប៉ារ៉ាស៊ីត ណេម៉ាតូត។ ចង្រ្កងស្វាស្លឹកធំអាចផលិតជីវម៉ាស់ខ្ពស់រហូតដល់ ៤ ទៅ ៧ តោន/ហិកតា ជីវម៉ាសស្ងួតសូម្បីតែនៅលើដីខ្សត់ជីជាតិ។ វាអាចចាប់យកអាសូត(N) ពីបរិយាកាស ពី ៥០ទៅ១០០គីឡូក្រាម/ហិកតា។ វាមានអត្ថប្រយោជន៍ក្នុងការកាត់បន្ថយការហូរច្រោះដី ការបំបែកស្រទាប់ហាប់ណែន បង្កើនសារធាតុមីក្រូសរីរាង្គដី ធ្វើឱ្យប្រសើរឡើងនូវទម្រង់ដី រក្សាសំណើមដី គ្រប់គ្រងនិងកាត់បន្ថយស្មៅចង្រៃ ព្រមទាំងបង្កើនពពួកសត្វល្អិតមានប្រយោជន៍នានាផងដែរ។

**ខ. បច្ចេកទេសដាំដុះក្នុងផលិតកម្មគ្រាប់ពូជ**

ចង្រ្កង់ស្វាស្លឹកធំ គឺជាប្រភេទដំណាំដែលធន់នឹងភាពរាំងស្ងួត (តែមិនធន់នឹងទឹកទេ) អាចដាំដុះបានលើដីច្រើនប្រភេទ និងគ្រប់តំបន់នៅប្រទេសកម្ពុជា។ ចង្រ្កង់ស្វាស្លឹកធំ គឺជាប្រភេទដំណាំមិនប្រកាន់រដូវ មានអាយុកាលពី ១០៥ ទៅ ១២០ថ្ងៃ។ បរិមាណគ្រាប់ពូជសម្រាប់ដាំដុះ ២០គីឡូក្រាម/ហិកតា សម្រាប់ការដាំដោយម៉ាស៊ីន និង ៣០ គីឡូក្រាម/ហិកតា សម្រាប់ការពង្រោះដោយដៃ។ ការដាំដោយម៉ាស៊ីន ប្រើចន្លោះជួរ ២៣ សង់ទីម៉ែត្រ ជម្រៅ ៣សង់ទីម៉ែត្រ។ ការរៀបចំដី គឺត្រូវរៀបចំឱ្យបានស្អាត សម្អាតស្មៅចង្រៃនានាមុនដាំដុះនិងគួរមានការកៀរពង្រាបដីឱ្យស្មើករណីដាំដុះដោយម៉ាស៊ីន។ រីឯការព្រោះដោយដៃគឺបន្ទាប់ពីក្ដួររាស់ដីរួចបាចគ្រាប់ពូជដំណាំគម្របដី រួចរាស់លុបដោយគោយន្ត ឬត្រាក់ទ័រ។




**រូបភាពទី១** ឧទាហរណ៍នៃការដាំដុះដំណាំគម្របដីនៅក្នុងរដូវវស្សា(ដាំតែ១វគ្គ) ដោយចាប់ផ្តើមពីខែសីហា




**រូបភាពទី២** ការដាំដុះដំណាំគម្របដីនៅចុងរដូវវស្សាក្នុងវគ្គទី២បន្ទាប់ពីដំណាំពោត នៅក្នុងខែកញ្ញា


ការកៀរពង្រាបដីឱ្យបានស្អាតមុនដាំ


ការដាំដុះដោយម៉ាស៊ីនលើដីស្អាត


ការដាំដុះដោយម៉ាស៊ីនដាំអត់ភ្ជួរលើដីចម្ការ ដែលទើបប្រមូលផលពោតរួច


**រូបភាពទី៣** ការដាំដុះដំណាំគម្របដីចង្ក្រង់ស្វាស្លឹកធំនៅចន្លោះដំណាំស្វាយ

ចង្ក្រង់ស្វាស្លឹកធំចាប់ផ្តើមចេញផ្កានៅអាយុពី៥០ទៅ៦០ថ្ងៃក្រោយដាំ និងអាចចាប់ផ្តើមប្រមូលផលនៅអាយុ១០០ ទៅ១២០ ថ្ងៃក្រោយដាំ ពេលស្លឹកជ្រុះអស់៨០ទៅ៩០% ផ្លែប្រែទៅជាពណ៌ស និងគ្រាប់ប្រែជាពណ៌ត្នោតក្រម៉ៅ ឬខ្មៅ។ កសិករអាចពន្យារពេលប្រមូលផលដើម្បីឱ្យផ្លែទុំស្មើគ្នាលើស៩០%។ សម្រាប់ការប្រមូលផល កសិករអាចប្រមូលផលដោយច្រូតនឹងម៉ាស៊ីន(ម៉ាស៊ីនច្រូតស្រូវ) និងច្រូតដោយដៃរួចត្រូវបោកយកគ្រាប់ជាមួយម៉ាស៊ីនបោកស្រូវ។ ទិន្នផលទទួលបានអាចចន្លោះ ៣៥០-១,០០០ គីឡូក្រាម/ហិកតា អាស្រ័យទៅតាមតំបន់ និងរដូវកាលដាំដុះ។ បន្ទាប់ពីច្រូតកាត់រួចកសិករត្រូវសម្អាតគ្រាប់ពូជ រែង រោយ និងសម្ងួតឱ្យបានស្ងួតល្អក្នុងរយៈពេលពី៣-៤ថ្ងៃ ដោយរក្សាសំណើមតិចជាង ៩% មុនពេលយកទៅរក្សាទុកនៅកន្លែងស្ងួត និងវេចខ្ចប់សម្រាប់ពូជ។



ចង្រ្កង់ស្វាស្លឹកធំនៅ អាយុ៣០ថ្ងៃ | ចង្រ្កង់ស្វាស្លឹកធំនៅ អាយុ៦០ថ្ងៃ | ចង្រ្កង់ស្វាស្លឹកធំនៅ អាយុ៩០ថ្ងៃ | ចង្រ្កង់ស្វាស្លឹកធំនៅ អាយុ១០០ថ្ងៃ

**រូបភាពទី៤** វដ្តនៃការលូតលាស់ដំណាំគម្របដីចង្រ្កង់ស្វាស្លឹកធំ

សម្រាប់ការទុកដាក់ក្រោយពេលប្រមូលផល និងហាលសម្ងួតរួចត្រូវវេចខ្ចប់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដើម្បីថែរក្សាគុណភាពគ្រាប់ពូជ ឬច្រកទុកក្នុងធុងជ័រ ករណីរក្សាទុកផលិតពូជបន្ត និងរក្សាទុកកន្លែងស្ងួត និងម្លប់។



**រូបភាពទី៥.** ការរក្សាទុកគ្រាប់ពូជចង្រ្កង់ស្វាស្លឹកធំ

### ៣.២.២ បច្ចេកទេសដាំដុះដំណាំគម្របដីចង្រ្កង់ស្វាស្លឹកតូច

#### ក. លក្ខណៈទូទៅ

ចង្រ្កង់ស្វាស្លឹកតូច មានឈ្មោះវិទ្យាសាស្រ្តថា Crotalaria ochroleuca និងជាភាសាអង់គ្លេស Rattlepod។ ចង្រ្កង់ស្វាស្លឹកតូចជាប្រភេទដំណាំគម្របដីដែលមានអាយុកាលវែងមធ្យម និងប្រកាន់រដូវ មានដើមដុះត្រង់ មានមែកច្រើន និងមានកម្ពស់រហូតដល់ជាង៣ម៉ែត្រ។ ស្លឹកមានលក្ខណៈឆ្លាស់គ្នា ទម្រង់ជា៣ស្លឹក និងមានទងស្លឹក ប្រវែង ២-៦ សង់ទីម៉ែត្រ។ ផ្កាមានពណ៌លឿងទៅលឿងខ្ចី មានផ្លែតូចរាងស៊ីឡាំងមានប្រវែង ៣៥-៥០ម.ម ទទឹង ៥-៧ម.ម មានគ្រាប់ច្រើនទំហំតូច និងប្រវែងផ្លែ ៣,៥សង់ទីម៉ែត្រ មានសំបកពណ៌បៃតងនៅពេលខ្ចី ពេលទុំមានពណ៌ក្រម៉ៅ។ គ្រាប់ពូជក្នុងមួយគីឡូក្រាមមានចំនួនប្រហែល ២០០,០០០គ្រាប់។ គ្រាប់ពូជចង្រ្កង់ស្វាស្លឹកតូចមានភាពងាយស្រួលក្នុងការដាំដុះ និងអាចផ្តល់ទិន្នផលជាមធ្យមប្រមាណ ៧៥០គីឡូក្រាម/ហិកតា។

#### ខ. បច្ចេកទេសដាំដុះក្នុងការផលិតពូជ

ចង្រ្កង់ស្វាស្លឹកតូច ជាប្រភេទដំណាំប្រកាន់រដូវ ដែលត្រូវប្រមូលផលនៅកំឡុងខែធ្នូ-មករា (ការដាំដុះនៅក្នុងកំឡុងខែផ្សេងទទួលបានគ្រាប់មិនល្អ)។ បន្ទាប់ពីមានភ្លៀងគ្រប់គ្រាន់ កសិករអាចដាំដោយម៉ាស៊ីនក្នុងបរិមាណ ៦-៨ គីឡូក្រាម/ហិកតា ឬព្រោះដោយដៃក្នុងបរិមាណ ១០-១២គីឡូក្រាម/ហិកតា និង ១៤គីឡូក្រាម/ហិកតា

សម្រាប់ដីខ្សាច់ដីជាតិ ដែលអាចដាំដុះចាប់ពីខែមិថុនាដល់ដើមខែកញ្ញា។ ការដាំក្រោយខែសីហា មានហានិភ័យខ្ពស់ ដែលធ្វើឱ្យទិន្នផលថយចុះ ដោយសាររាំងស្ងួត និងក្ដៅខ្លាំងធ្វើឱ្យផ្កាជ្រុះច្រើន។ សម្រាប់ការដាំដោយម៉ាស៊ីន ប្រើចន្លោះជួរ ៦០សង់ទីម៉ែត្រ ជម្រៅ ៣,៥សង់ទីម៉ែត្រ ហើយការរៀបចំដី គឺត្រូវរៀបចំឱ្យបានស្អាត សម្អាតស្មៅចង្រៃនានា មុនដាំដុះ និងគួរមានការកៀរពង្រាបដី។ រីឯការពង្រោះដោយដៃគឺ បន្ទាប់ពីភ្ជួររាស់ដីរួច បាចគ្រាប់ពូជដំណាំគម្របដី រួចរាស់លុបដោយគោយន្ត ឬត្រាក់ទ័រ។




**រូបភាពទី៧** ការដាំដុះដំណាំគម្របដីនៅចុងរដូវវស្សាក្នុងវគ្គទី២បន្ទាប់ពីដំណាំពោត នៅក្នុងដើមខែកញ្ញា




ចង្រ្កង់ស្វាស្លឹកតូចដាំនៅចន្លោះស្វាយចន្ទី ចង្រ្កង់ស្វាស្លឹកតូចផ្លែទុំត្រៀមប្រមូលផល

**រូបភាពទី៨** ការដាំដុះដំណាំគម្របដីចង្រ្កង់ស្វាស្លឹកតូចនៅក្នុងចម្ការស្វាយចន្ទី

ក្រោយពីដាំបានរយៈពេល៣០ទៅ៣៥ថ្ងៃ ចាប់ផ្ដើមឃើញមានវត្តមានពពួកស្មៅចង្រៃក្រុមស្លឹកធំ (ម្អមភ្នំ, សិរមាន់ព្រៃ) និងក្រុមពពួកស្មៅស្លឹកតូច ស្មៅកន្ទុយចចក។ ពេលត្រួតពិនិត្យគ្រាប់ពូជនៅក្នុងចម្ការត្រូវពិនិត្យមើលពពួកស្មៅកន្ទុយចចក ករណីមានតិចជាង១០% មិនចោទជាបញ្ហានោះទេ ព្រោះគ្រាប់ស្មៅនឹងត្រូវបានសម្អាតជាមួយម៉ាស៊ីនបោកនៅបន្ទាប់ពីប្រមូលផលរួច។







ដំណាក់កាលលូតលាស់៦០ថ្ងៃ ក្រោយដាំ | ដំណាក់កាលចេញផ្កានិងផ្លែ នៅអាយុកាល៩៥ ថ្ងៃ | ដំណាក់កាលទុំនៅអាយុ កាល ១៣០ថ្ងៃ

**រូបភាពទី៩** វដ្តនៃការលូតលាស់ដំណាំគម្របដីចង្រ្កង់ស្វាស្លឹកតូច

រយៈពេលនៃការចេញផ្កានិងផ្លែបន្ទាប់ពីដាំបានចន្លោះពី៧០ថ្ងៃ រហូតដល់១០០ថ្ងៃ ហើយផ្កានិងផ្លែមាននៅចុងមែកនៃដើម។ ការប្រមូលផលគឺធ្វើឡើងបន្ទាប់ពីដាំបាន១២០ទៅ១៣០ថ្ងៃ រហូតដល់សំបកគ្រាប់ឡើងពណ៌ខ្មៅ និងជ្រុះស្លឹក (អាចទុកប្រមូលផលរហូតដល់ជ្រុះស្លឹកអស់៨០%ទៅ៩០) ទិន្នផលទទួលបានអាចចន្លោះ ៣៥០-១,០០០ គីឡូក្រាម/ហិកតា អាស្រ័យទៅតាមតំបន់និងរដូវកាលដាំដុះ។ បន្ទាប់ពីប្រមូលផលរួចត្រូវសម្អាតគ្រាប់ពូជ រែង រោយ និងសម្ងួតឱ្យបានស្ងួតល្អក្នុងរយៈពេល ពី៣-៤ថ្ងៃ ដោយរក្សាសំណើមតិចជាង ៩% មុនពេលយកទៅរក្សាទុកនៅកន្លែងស្ងួត និងវេចខ្ចប់សម្រាប់ទុកពូជ។

### ៣.២.៣ បច្ចេកទេសដាំដុះដំណាំស្មោរគោក

ស្មោរគោក ជារុក្ខជាតិស្ថិតក្នុងអំបូរសណ្ដែក មានឈ្មោះវិទ្យាសាស្ត្រ *Sesbania sesban* និងឈ្មោះជាភាសាអង់គ្លេស Sesban។ ស្មោរគោកជាដំណាំប្រកាន់រដូវ មានអាយុកាល៤ខែ ការប្រមូលផលនៅកំឡុងខែវិច្ឆិកា និងខែធ្នូ។ ការដាំដុះនៅដើមខែសីហាសម្រាប់តំបន់ដែលពឹងផ្អែកលើរបបទឹកភ្លៀង។ ការដាំដុះដោយម៉ាស៊ីន បរិមាណគ្រាប់ពូជពី ៩ទៅ១០គីឡូក្រាម/ហិកតា មានចន្លោះជួរ ៤០ទៅ៦០សង់ទីម៉ែត្រ ជម្រៅ ៣,៥សង់ទីម៉ែត្រ។ សម្រាប់ការពង្រោះដោយដៃ បរិមាណគ្រាប់ពូជពី១២ទៅ១៤គីឡូក្រាម/ហិកតា។ ក្រោយពីដាំបានរយៈពេលពី៣០ទៅ៣៥ថ្ងៃ មានវត្តមានពពួកស្មៅចង្រៃក្រុមស្មៅស្លឹកធំ និងស្មៅស្លឹកតូច ស្មៅកន្ទុយចចក និងរយៈពេលពី៥០ទៅ៦០ថ្ងៃ មានសត្វល្អិតដូចជាដង្កូវបំផ្លាញស្លឹកតិចតួចប៉ុន្តែមិនប៉ះពាល់ដល់ទិន្នផលទេ។ ស្មោរគោកចាប់ផ្ដើមចេញផ្កា និងផ្លែនៅខែតុលា ការប្រមូលផលកំឡុងខែវិច្ឆិកា បន្ទាប់ពីផ្លែទុំចន្លោះពី៧០%ទៅ៨០% ពេលសំបកគ្រាប់ប្រែពណ៌ក្រម៉ៅ និងរឹង ទិន្នផលចន្លោះពី ៦០០-៨០០គីឡូក្រាម/ហិកតា។





**រូបភាពទី១០**. ការដាំដុះដោយម៉ាស៊ីនចន្លោះជួរ និងការដាំដុះដោយដៃ

### ៣.២.៤ ការត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាល

ការត្រួតពិនិត្យគុណភាពផលិតកម្មពូជដំណាំគម្របដីនៅទីវាលធ្វើឡើង តែមួយលើកសម្រាប់មួយប្រភេទពូជក្នុងដំណាក់កាលចេញផ្កា។ ការត្រួតពិនិត្យត្រូវជ្រើសរើសចម្ការដោយចៃដន្យលើផ្ទៃដី១០ភាគរយនៃផ្ទៃដីផលិតកម្មគ្រាប់ពូជសរុប។ ទិដ្ឋភាពនៃការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល មានដូចខាងក្រោម៖

- ពិនិត្យប្រភពគ្រាប់ពូជយកមកប្រើប្រាស់ក្នុងផលិតកម្ម ដូចជា ព័ត៌មានលើសំបកវេចខ្ចប់ វិក្ក័យបត្រ និង ប្រវត្តិដាំដុះនៃចម្ការផលិតកម្ម
- ផ្ទៃដីត្រូវត្រួតពិនិត្យ ចំនួន ៥កន្លែង ដែល៤ម$^{២}$/កន្លែង ដើម្បី៖
  - រាប់ចំនួនដើមពូជលាយ
  - រាប់ចំនួនស្មៅហាមឃាត់
  - វាយតម្លៃភាគរយនៃការបំផ្លាញដោយជំងឺហាមឃាត់ក្នុងចម្ការផលិតកម្មគ្រាប់ពូជទាំងមូល។
- វិធីសាស្ត្រក្នុងការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល អាចយកជារាងអក្សរ X ឬអក្សរ W

## ៣.៣ ផ្ទៀងផ្ទាត់ប្រភពគ្រាប់ពូជ

១. ក្នុងដំណាក់កាលត្រួតពិនិត្យគុណភាពផលិតកម្មទីវាល ត្រូវត្រួតពិនិត្យស្លាកសញ្ញាបាវវេចខ្ចប់គ្រាប់ពូជថាជា ពូជសុទ្ធមានគុណភាពល្អ។

២.គ្រាប់ពូជត្រូវមានប្រភពច្បាស់លាស់អំពីអង្គភាព ឬគ្រឹះស្ថានផលិតគ្រាប់ពូជ ដែលមានការអនុញ្ញាស្របច្បាប់ ដែលបានទទួលស្គាល់ដោយនាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម។ល។

៣. ណែនាំអ្នកផលិតគ្រាប់ពូជឱ្យរក្សាទុកសំបកវេចខ្ចប់គ្រាប់ពូជ និងវិក្កយបត្រសម្រាប់គោលបំណងនៃការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល។




**សំបកបាវវេចខ្ចប់**




**វិក្កយបត្រ**

### ៣.៤ លក្ខខណ្ឌសម្រាប់ជ្រើសរើសចម្ការផលិតកម្មពូជដំណាំគម្របដី

១.សម្រាប់ការផលិតពូជដំណាំគម្របដី ត្រូវជ្រើសយកចម្ការដែលដាំដំណាំគម្របដីនៅរដូវមុនជាប្រភេទពូជដំណាំគម្របដីក្នុងប្រភេទតែមួយ ឬដីថ្មីមិនធ្លាប់ធ្វើការដាំដុះ ឬដំណាំចម្បងនានាដូចជា ពោត ស្រូវ សណ្តែក...។

២.ទំហំផ្ទៃដីផលិតកម្មអប្បបរមារបស់អ្នកផលិតពូជ ដែលសមស្របនិងអនុញ្ញាត ០.៥០ ហ.ត

៣.ចម្ការផលិតកម្មគ្រាប់ពូជ ត្រូវរក្សាគម្លាតចេញរបង ឬព្រំចម្ការ ២ម៉ែត្រ

| រដូវដាំដុះមុន | ផលិតកម្មគ្រាប់ពូជតាម ប.គ.ព |
|---|---|
|  ចង្រ្កង់ស្វាស្លឹកធំ ( Crotalaria Juncea ) |   ចង្រ្កង់ស្វាស្លឹកធំ ( Crotalaria Juncea ) |
|  ចង្រ្កង់ស្វាស្លឹកតូច ( Crotalaria Ochroleuca ) |   ចង្រ្កង់ស្វាស្លឹកធំ ( Crotalaria Juncea ) |
|  ពោត |   ចង្រ្កង់ស្វាស្លឹកធំ ( Crotalaria Juncea ) |
|  ស្រូវ |   ចង្រ្កង់ស្វាស្លឹកធំ ( Crotalaria Juncea ) |







### ៣.៥ ស្តង់ដារគុណភាពផលិតកម្មនៅទីវាល

ស្តង់ដារទីវាលបានកំណត់កម្រិតអនុញ្ញាតអតិបរមាសម្រាប់ដំណាំគម្របដី ដូចខាងក្រោម ៖

| ប្រភេទ | បរិយាយលម្អិត | ស្តង់ដារក្នុងផ្ទៃដីទំហំ ២០ម² | |
|---|---|---|---|
| | | ចំណាត់ថ្នាក់ចុះបញ្ជី | ចំណាត់ថ្នាក់វិញ្ញាបនបត្រ |
| ពូជលាយ | ពូជដំណាំផ្សេង | ៦ដើម | ១០ដើម |
| ស្មៅហាមឃាត់ | ១.ស្មៅដំរី (*Pennisetum purpureum*) ២.ទឹកដោះខ្លាធំ (*Euphorbia heterophylla*) ៣.ក្រដិប (*Pentapetes Phoenicea*) | ១០ដើម | ១៥ដើម |
| ជំងឺហាមឃាត់ | ១.ជំងឺផ្សិតច្រែះ (*rust disease*) | មិនលើសពី៥០% នៃផ្ទៃចម្ការផលិតកម្មដែលបានត្រួតពិនិត្យគុណភាពផលិតកម្មទីវាល | |

### ៣.៦ ការកំណត់ប្រភេទពូជលាយ

ពូជលាយរបស់ដំណាំគម្របដីចង្រ្កង់ស្វាស្លឹកធំ ចង្រ្កង់ស្វាស្លឹកតូច និងស្នោរគោក ត្រូវត្រួតពិនិត្យមើល រូបរាង និងពណ៌។

### ៣.៧ ការកំណត់ស្មៅហាមឃាត់

ប្រភេទស្មៅហាមឃាត់នៅក្នុងប្រព័ន្ធផលិតកម្មពូជដំណាំចង្រ្កង់ស្វាស្លឹកធំ ចង្រ្កង់ស្វាស្លឹកតូច និងស្នោរគោក ដែលតែងតែសង្កេតឃើញមានក្នុងចម្ការដូចជាស្មៅដំរី (*Pennisetum purpureum*) ក្រជិប (*Pentapetes Phoenicea*) និងស្មៅទឹកដោះខ្លាធំ (*Euphorbia heterophylla*) និងពិបាកក្នុងការគ្រប់គ្រង ហើយពួកវាអាចផលិតគ្រាប់ពូជបាន យ៉ាងច្រើនសម្រាប់រដូវកាលបន្ទាប់។




**រូបភាពទី១២** ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលនៅដំណាក់កាលមុនពេលប្រមូលផល



ប្រភពរូបថត CABI Digital library

**រូបភាពទី១៣** ស្មៅដំរី (ឆ្វេង) និងទឹកដោះខ្លាធំ (ស្តាំ)

## ៣.៨ ការកំណត់ជំងឺហាមឃាត់

ការកំណត់ជំងឺហាមឃាត់ដែលភាគច្រើនកើតមានលើពពួកដំណាំគម្របដី ចង្រ្គង់ស្វាស្លឹកធំ ចង្រ្គង់ស្វាស្លឹកតូច និងស្មៅរគោក គឺជំងឺផ្សិតច្រែះ (rust disease) ដែលបណ្តាលមកពីផ្សិតពណ៌លឿងស្រដៀងទៅនឹងច្រែះ ដែលកើតមានឡើងភាគច្រើននៅពេលមិនមានពន្លឺ និងខ្យល់គ្រប់គ្រាន់។ បើសង្កេតឃើញថាមានជំងឺនេះ អ្នកផលិតត្រូវដកដើមដែលកើតជំងឺចោល ដើម្បីការពារការរាលដាលទៅដើមផ្សេងទៀត។



**រូបភាពទី១៤** ដំណាំគម្របដីចង្រ្គង់ស្វាស្លឹកតូចដែលរងផលប៉ះពាល់ពីជំងឺផ្សិតច្រែះ

## ៣.៩ ការវិនិច្ឆ័យលើដំណាំគម្របដីទទួលរងប៉ះពាល់ដោយសារតែជំងឺហាមឃាត់

ជំងឺកើតលើដំណាំគម្របដីវាអាចកើតនៅកន្លែងខ្លះ ឬនៅផ្តុំគ្នាហើយអាចរាលដាលកាន់តែច្រើន ដូច្នេះ ប្រសិនបើធ្វើការវាយតម្លៃ ឃើញការបំផ្លាញតិចជាង ៥០% គឺត្រូវបានអនុញ្ញាតប្រមូលផលទុកជាពូជ។ ប្រសិនបើមានការបំផ្លាញច្រើនជាង៥០%គឺមិនអាចទុកជាគ្រាប់ពូជបានទេ។




២៥%
ដំណាំដែលរងការបំផ្លាញក្នុងកម្រិតទទួលយកបាន

>៥០%
ដំណាំដែលរងការបំផ្លាញក្នុកម្រិតលើសស្តង់ដារ

## ៤. ការត្រួតពិនិត្យគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍

### ៤.១ ដំណើរការត្រួតពិនិត្យគុណភាពក្នុងមន្ទីរពិសោធន៍

១.គំនូសបំព្រួញដំណើរការយកសំណាកគ្រាប់ពូជ

**ផលិតផលគ្រាប់ពូជ ៖** មន្ត្រីត្រួតពិនិត្យគុណភាពយកសំណាកដោយអនុលោមទៅតាមវិធានដែលមានចែង

↓

**សំណាកបឋម៖** សំណាកយកចេញពីបាវគ្រាប់ពូជនីមួយៗ ដោយចៃដន្យតាមវិធានយកសំណាក

↓

**សំណាករួម៖** ប្រសិនបើសំណាកបឋមមានឯកសណ្ឋានភាពពេញលេញ គេត្រូវដាក់វាបញ្ចូលគ្នា

↓

**សំណាករួម៖** សំណាករួមអប្បបរមា៥០០ក្រាមត្រូវបញ្ជូនសម្រាប់ការត្រួតពិនិត្យគុណភាព

↓

**សំណាកបញ្ជូន៖** វេចខ្ចប់/បិទស្លាកសញ្ញា (ឡូត៍គ្រាប់ពូជ ឈ្មោះពូជ ថ្នាក់គ្រាប់ពូជ កាលបរិច្ឆេទ ប្រមូលផល និងអាសយដ្ឋាននៃអ្នកផលិតគ្រាប់ពូជ)

↓

**ការវិភាគគុណភាព៖** សំណាកអប្បបរមា ៥០០ ក្រាមត្រូវបានប្រើសម្រាប់វិភាគភាពសុទ្ធ និងបរិមាណ នៅសល់ទុកសម្រាប់វិភាគគុណភាពសារជាថ្មីក្នុងករណីចាំបាច់។

### ៤.២ ការយកសំណាកបឋម

យកសំណាកបឋមចេញពីបាវបានជ្រើសរើសដោយចៃដន្យ ដែលមានបរិមាណប្រហាក់ប្រហែលគ្នា ដាក់សំណាកបឋមចូលគ្នាទៅជាសំណាករួមតែមួយនៅពេលសំណាកបឋមមានឯកសណ្ឋានភាពពេញលេញ។

| ចំនួនបាវ | ចំនួនសំណាកត្រូវការ | ចំនួនបាវ | ចំនួនសំណាកត្រូវការ |
|---|---|---|---|
| ១-៤ | ១ សំណាកក្នុង ១បាវ | ១៦-៣០ | ៦ សំណាកពីបាវផ្សេងៗគ្នា |
| ៥-៨ | ៤ សំណាកពីបាវផ្សេងគ្នា | ៣១-៥៩ | ៧ សំណាកពីបាវផ្សេងៗគ្នា |
| ៩-១៥ | ៥ សំណាកពីបាវផ្សេងគ្នា | >៦០ | ៨ សំណាកពីបាវផ្សេងៗគ្នា |

## សូមប្រើដែកផាំយកសំណាកគ្រាប់ដើម្បីយកសំណាក



### ៤.៣ ការរៀបចំសំណាកដើម្បីពិសោធន៍

បន្ទាប់ពីប្រមូលសំណាកបឋមរួចរាល់ គេដាក់បញ្ចូលគ្នា និងច្របល់ឱ្យសព្វ ដោយសំណាកសម្រាប់មន្ទីរពិសោធន៍ត្រឹម ០.៥ គ.ក ប៉ុណ្ណោះ។ វិធីសាស្រ្តក្នុងការច្របល់សំណាក ៖

- លាយសំណាកបឋមច្របល់ចូលគ្នាឱ្យសព្វ
- ពុះសំណាកនោះជា ២ចំណែក និងបន្តពុះជា ៤ចំណែកទៀត
- រួចធ្វើការកំណត់ ដោយផ្នែកខាងលើខាងឆ្វេងជាផ្នែក ក ផ្នែកខាងលើខាងស្តាំជាផ្នែក ខ ផ្នែកខាងក្រោមខាងឆ្វេង ខ និងផ្នែកខាងក្រោមខាងស្តាំជាផ្នែក ក
- បន្ទាប់ចូកយកតែផ្នែក ក ឬ ខ ទាំងខាងលើ និងខាងក្រោម ចូលគ្នារួចថ្លឹងយកតែ ០.៥ គ.កប៉ុណ្ណោះ ដើម្បីពិសោធន៍ និងចំណែកដែលនៅសល់ទុកសម្រាប់សំណាកយោង



### ៩.៤ ការវេចខ្ចប់ និងបិទស្លាកសំណាកបញ្ជូន

- ត្រូវប្រេកគ្រាប់ពូជជាមួយថង់បិទជិត
- បរិមាណ ៥០០ ក្រាមនៃសំណាកបញ្ជូនត្រូវវេចខ្ចប់ដែលមានបិទស្លាកព័ត៌មាន
- ព័ត៌មានត្រូវសរសេរលើស្លាកសញ្ញា រួមមាន៖ ឡូត៍គ្រាប់ពូជ ឈ្មោះពូជ កាលបរិច្ឆេទ ប្រមូលផល និង អាសយដ្ឋានរបស់អ្នកផលិតគ្រាប់ពូជ




**ចំណាំ ៖ បរិមាណអតិបរមា ៥០០ ក្រាម នៃសំណាកដែលត្រូវបញ្ជូន**

### ៩.៥ ស្តង់ដារគុណភាពគ្រាប់ពូជ

#### ៩.៥.១ ស្តង់ដារគុណភាពគ្រាប់ពូជចង្រ្កង់ស្វាស្លឹកធំ

ស្តង់ដារគ្រាប់ពូជខាងក្រោមនេះ ប្រើសម្រាប់វិភាគពូជសុទ្ធ៖

| កត្តា | ថ្នាក់គ្រាប់ពូជ | |
|---|---|---|
| | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
| គ្រាប់ពូជសុទ្ធ(អប្បបរមា) | ៩៨% | ៩៨% |
| គ្រាប់ដំណាំផ្សេង (អតិបរមា) | ៣គ្រាប់ | ៦គ្រាប់ |
| កម្ទេចកម្ទីគ្រាប់ផ្សេងៗ(អតិបរមា) | ២% | ២% |
| អត្រាដំណុះគ្រាប់(អប្បបរមា) | ៨២% | ៨០% |
| សំណើមគ្រាប់(អតិបរមា) | ៨% | ៩% |

### ៤.៤.២ ស្តង់ដារគុណភាពគ្រាប់ពូជចង្រ្កង់ស្វាស្លឹកតូច

ស្តង់ដារគ្រាប់ពូជខាងក្រោមនេះ ប្រើសម្រាប់វិភាគពូជសុទ្ធ៖

| កត្តា | ថ្នាក់គ្រាប់ពូជ | |
|---|---|---|
| | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
| គ្រាប់ពូជសុទ្ធ(អប្បបរមា) | ៩៨% | ៩៨% |
| គ្រាប់ដំណាំផ្សេង (អតិបរមា) | ៣គ្រាប់ | ៦គ្រាប់ |
| កម្ទេចកម្ទីគ្រាប់ផ្សេងៗ(អតិបរមា) | ២% | ២% |
| អត្រាដំណុះគ្រាប់(អប្បបរមា) | ៨២% | ៨០% |
| សំណើមគ្រាប់(អតិបរមា) | ៨% | ៩% |

### ៤.៤.៣ ស្តង់ដារគុណភាពគ្រាប់ពូជស្មៅរគោក

ស្តង់ដារគ្រាប់ពូជខាងក្រោមនេះ ប្រើសម្រាប់វិភាគពូជសុទ្ធ៖

| កត្តា | ថ្នាក់គ្រាប់ពូជ | |
|---|---|---|
| | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
| គ្រាប់ពូជសុទ្ធ(អប្បបរមា) | ៩៨% | ៩៨% |
| គ្រាប់ដំណាំផ្សេង (អតិបរមា) | ៥គ្រាប់ | ១០គ្រាប់ |
| កម្ទេចកម្ទីគ្រាប់ផ្សេងៗ(អតិបរមា) | ២% | ២% |
| អត្រាដំណុះគ្រាប់(អប្បបរមា) | ៨០% | ៨០% |
| សំណើមគ្រាប់(អតិបរមា) | ៨% | ៨% |

## ៤.៥ ដំណើរការវិភាគសំណាកគ្រាប់ពូជដំណាំតម្រូវចិត្ត

ក្នុងដំណើរការវិភាគនេះ យើងត្រូវវិភាគដូចខាងក្រោម៖

- ✓ វិភាគរូបសាស្ត្រ
- ✓ វិភាគប្រភេទពូជ
- ✓ វិភាគសំណើម
- ✓ វិភាគដំណុះគ្រាប់
- ✓ សំណាកយោង

### ៤.៦.១ វិភាគរូបសាស្ត្រ

- យក១០០ក្រាមនៃសំណាកវិភាគ រួចរើសយកកម្ទេចកម្ទី ចេញ ដូចជា៖ ដុំថ្ម ដី គ្រាប់ពូជដំណាំផ្សេង គ្រាប់ខ្ទី គ្រាប់បាក់ដែលនៅសល់តិចជាង ៥០%
- ថ្លឹងទម្ងន់កម្ទេចកម្ទី សរុបនៃសំណាក បន្ទាប់មកគណនាភាគរយនៃគ្រាប់ពូជសុទ្ធ

រូបមន្តគណនាភាគរយពូជសុទ្ធគ្រាប់៖

$$\text{កម្ទេចកម្ទី (\%)} = \frac{\text{ទម្ងន់កម្ទេចកម្ទី (ក្រាម)}}{\text{ទម្ងន់សំណាក (៧០ក្រាម)}} \times ១០០$$

$$\text{គ្រាប់ពូជសុទ្ធ (\%)} = ១០០ \text{ (\%)} - \text{កម្ទេចកម្ទី (\%)}$$

### ៤.៦.២ វិភាគប្រភេទពូជ

- រាប់ចំនួនគ្រាប់ពូជផ្សេងដែលមាន និងគ្រាប់ពូជដែលខូច ស្ថិតក្នុងសំណាកវិភាគ ១០០ក្រាម
- ពិនិត្យមើលពណ៌ និងទ្រង់ទ្រាយដើម្បីកំណត់គ្រាប់ពូជផ្សេង នៅលើបន្ទះក្ដារ វិភាគគ្រាប់ពូជ
- ពិនិត្យមើលកម្ទេចកម្ទី ដទៃទៀត ដូចជា៖ គ្រាប់ខ្ទីដែលនៅសល់ក្រោម៥០% ដុំថ្ម ឬវត្ថុធាតុផ្សេងទៀត។

### ៤.៦.៣ វិភាគសំណើមគ្រាប់

